**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ១៤៧ .អនក្រ.បក

**អនុក្រឹត្យ**

**ស្ដីពី**

**ការកាត់ចេញពីដីគម្របព្រៃឈើ បំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងពីដីក្រុមហ៊ុន ឬស្សី នូវផ្ទៃដីទំហំ ៩២៧២ ហិកតា និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៣៥៥១ គ្រួសារ ដែលបាន កាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង នៅស្រុក រតនៈមណ្ឌល ស្រុក បាណន់ និងស្រុកបវេល ខេត្តបាត់ដំបង**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យ ប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យ ប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ ១៣២១ របប ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ចេញពីដីតម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងពីដី ក្រុមហ៊ុន ឬស្សី នូវផ្ទៃដីទំហំ ៩២៧២ ហិកតា និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ នៅខេត្តបាត់ដំបង ស្ថិតនៅក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

១.១. ផ្ទៃដីទំហំ ១៣៥៤ ហិកតា នៅភូមិអូរដា ឃុំផ្លូវមាស ស្រុក រតនៈមណ្ឌល តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (1) នៃអនុក្រឹត្យនេះ

១.២. ផ្ទៃដីទំហំ ៤១៩៣ ហិកតា នៅភូមិបុះខ្នុរ ឃុំចែងមានជ័យ ស្រុក បាណន់ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (2) នៃអនុក្រឹត្យនេះ

១.៣. ផ្ទៃដីទំហំ ១៦៨១ ហិកតា នៅភូមិស្លាប៉ាង ឃុំតាក្រាម ស្រុក បាណន់

១.៤. ផ្ទៃដីទំហំ ២០៤៤ ហិកតា នៅភូមិទំនប់តាកួន ឃុំឃ្លាំងមាស ស្រុកបវេល

ចំណុច ១.៣ និង១.៤ ខាងលើ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (3) នៃអនុក្រឹត្យនេះ

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការ គ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ៣៥៥១ គ្រួសារ នៅក្នុងភូមិដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋ ចំនួន ១៣៨៤ គ្រួសារ នៅភូមិអូរដា ឃុំផ្លូវមាស ស្រុករតនៈមណ្ឌល

- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋចំនួន ១២៥០ គ្រួសារ នៅភូមិបុះខ្នុរ ឃុំចែងមានជ័យ ស្រុក បាណន់
- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋចំនួន ៥៧៣ គ្រួសារ នៅភូមិស្លាប៉ាង ឃុំតាក្រាម ស្រុក បាណន់
- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋចំនួន៣៨៤ គ្រួសារ នៅភូមិទំនប់តាកួន ឃុំឃ្លាំងមាស ស្រុក បវេល

**មាត្រា ៣ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ១១ ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធ ៣

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...១៧៤ អនក្រ.បក ចុះថ្ងៃទី...១៩...ខែ...ធ្នូ......ឆ្នាំ២០១២ ស្តីពីការកាត់ចេញពីដីគម្របព្រៃឈើ ចំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងពីដីក្រុមហ៊ុន ឫស្សី នូវផ្ទៃដីទំហំ៥២៧២ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៥៥១គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុកគោះក្រឡ មណ្ឌល ស្រុកបាណន់ និងស្រុកបវេល ខេត្តបាត់ដំបង




| | | | | | |
|---|---|---|---|---|---|
| ចំណុចនិយាមការ | | | | | |
| ល.រ | X | Y | ល.រ | X | Y |
| 1 | 272137 | 1447629 | 24 | 264540 | 1442021 |
| 2 | 272129 | 1447081 | 25 | 264972 | 1442722 |
| 3 | 271989 | 1446356 | 26 | 265750 | 1442712 |
| 4 | 271894 | 1445557 | 27 | 265397 | 1443710 |
| 5 | 271938 | 1443982 | 28 | 265818 | 1443706 |
| 6 | 272451 | 1443982 | 29 | 265937 | 1445302 |
| 7 | 272451 | 1442070 | 30 | 267226 | 1445336 |
| 8 | 273095 | 1442128 | 31 | 267245 | 1446879 |
| 9 | 273781 | 1442062 | 32 | 269024 | 1447370 |
| 10 | 273961 | 1440375 | 33 | 270877 | 1447668 |
| 11 | 273061 | 1440380 | 34 | 270699 | 1445640 |
| 12 | 271709 | 1439830 | 35 | 271007 | 1445504 |
| 13 | 271698 | 1439627 | 36 | 271029 | 1443596 |
| 14 | 269519 | 1439603 | 37 | 270345 | 1440965 |
| 15 | 269504 | 1439238 | 38 | 268979 | 1440852 |
| 16 | 268282 | 1439076 | 39 | 268600 | 1440777 |
| 17 | 267472 | 1438581 | 40 | 268511 | 1441269 |
| 18 | 266541 | 1438683 | 41 | 268125 | 1441862 |
| 19 | 267090 | 1441167 | 42 | 267477 | 1442331 |
| 20 | 265667 | 1441602 | 43 | 268486 | 1445191 |
| 21 | 265543 | 1441249 | 44 | 269047 | 1445783 |
| 22 | 264971 | 1441629 | 45 | 269418 | 1445947 |
| 23 | 264872 | 1442040 | 46 | 270663 | 1445782 |

គម្របព្រៃឈើ

ព្រៃរបោះ

ព្រៃមិនមែនព្រៃ

អនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ ផ្ទៃដីទំហំ១៣៣០ហិកតា

**ប្រព័ន្ធកូអរដោនេ :**

តំបន់ទី : 48N

ចំណោលផែនទី : UTM

មិន្ទន័យយោង : WGS1984

**ប្រភពទិន្នន័យ:**

ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ

គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២



ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.១៧៥អនក្រ.បក ចុះថ្ងៃទី..១៩....ខែ..តុលា......ឆ្នាំ២០១២ ស្តីពីការកាត់ចេញពីដីគម្របព្រៃឈើ ចំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងពីដីក្រុមហ៊ុន ឫស្សី ខុមផ្ទៃដីទំហំ៥២៧២ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៥៥១គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុកគេនៈមណ្ឌល ស្រុកបាណន់ និងស្រុកបវេល ខេត្តបាត់ដំបង




| ចំនុចទីតាំងមុំ | | | | | |
|---|---|---|---|---|---|
| ល.រ | X | Y | ល.រ | X | Y |
| 1 | 294686 | 1421216 | 24 | 286743 | 1414044 |
| 2 | 295534 | 1417762 | 25 | 286801 | 1414359 |
| 3 | 295310 | 1417561 | 26 | 286662 | 1415027 |
| 4 | 295501 | 1415287 | 27 | 286935 | 1415975 |
| 5 | 295268 | 1415398 | 28 | 286561 | 1416081 |
| 6 | 295267 | 1415260 | 29 | 286917 | 1416685 |
| 7 | 293838 | 1415283 | 30 | 286673 | 1417622 |
| 8 | 293551 | 1415452 | 31 | 286885 | 1418192 |
| 9 | 293607 | 1415146 | 32 | 287582 | 1418712 |
| 10 | 293334 | 1415082 | 33 | 287697 | 1419112 |
| 11 | 292934 | 1414923 | 34 | 288007 | 1419271 |
| 12 | 292729 | 1414911 | 35 | 288250 | 1418951 |
| 13 | 292675 | 1415162 | 36 | 289196 | 1418632 |
| 14 | 292065 | 1415085 | 37 | 289645 | 1418522 |
| 15 | 291864 | 1414715 | 38 | 291133 | 1418989 |
| 16 | 291868 | 1414367 | 39 | 291138 | 1419324 |
| 17 | 291452 | 1414348 | 40 | 292657 | 1420047 |
| 18 | 291503 | 1414120 | 41 | 294469 | 1420552 |
| 19 | 289753 | 1413674 | 42 | 294499 | 1420668 |
| 20 | 289715 | 1413836 | 43 | 294537 | 1420876 |
| 21 | 289049 | 1413811 | 44 | 294675 | 1421041 |
| 22 | 288564 | 1414304 | 45 | 294589 | 1421022 |
| 23 | 287669 | 1414291 | 46 | 294449 | 1421221 |

ឧបសម្ព័ន្ធ ១

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ [illegible] អនក្រ.បក ចុះថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១២ ស្ដីពីការកាត់ចេញពីដីគម្របព្រៃឈើ បំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងពីដីក្រុមហ៊ុន ឫស្សី នូវផ្ទៃដីទំហំ៩២៧២ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៥៤១គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង នៅស្រុករតនៈមណ្ឌល ស្រុកបាណន់ និងស្រុកបវេល ខេត្តបាត់ដំបង




| ល.រ | X | Y | ល.រ | X | Y |
|---|---|---|---|---|---|
| 1 | 260646 | 1414204 | 19 | 258642 | 1408861 |
| 2 | 260492 | 1413726 | 20 | 257953 | 1408925 |
| 3 | 260834 | 1413556 | 21 | 257500 | 1409362 |
| 4 | 260878 | 1413433 | 22 | 257094 | 1409764 |
| 5 | 260816 | 1412048 | 23 | 256932 | 1410022 |
| 6 | 260592 | 1411754 | 24 | 257174 | 1410519 |
| 7 | 260880 | 1410845 | 25 | 257213 | 1411089 |
| 8 | 261143 | 1410677 | 26 | 257148 | 1411365 |
| 9 | 260953 | 1410108 | 27 | 257532 | 1411546 |
| 10 | 260547 | 1410022 | 28 | 257668 | 1411838 |
| 11 | 260179 | 1409493 | 29 | 257317 | 1412142 |
| 12 | 260240 | 1410051 | 30 | 257472 | 1412677 |
| 13 | 259483 | 1410120 | 31 | 257913 | 1412812 |
| 14 | 259505 | 1409705 | 32 | 258450 | 1413215 |
| 15 | 259365 | 1409466 | 33 | 259385 | 1413662 |
| 16 | 258996 | 1409261 | 34 | 259471 | 1413988 |
| 17 | 259141 | 1408191 | 35 | 260130 | 1414041 |
| 18 | 258651 | 1408522 | | | |

មាត្រដ្ឋាន 1:50,000

1 0.5 0 1 Kilometers

គម្របព្រៃឈើ

ព្រៃរបោះ

ព្រៃស្រោង

ព្រៃល្បោះ

ព្រៃលិចទឹកលាយព្រៃស្រោង

ដីមិនមែនព្រៃ

ព្រំប្រទល់ដីស្នើសុំ

ព្រំប្រទល់ដីភ្នំ
(ផ្ទៃដីភ្នំសរុបចំនួន១១២ហិកតា)

**ប្រព័ន្ធកូអរដោនេ :**

តំបន់ទី : 48N

ចំណោលផែនទី : UTM

ទិន្នន័យយោង : WGS1984

**ប្រភពទិន្នន័យ:**

ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ

គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២

